## សកម្មភាព១.៩: អាគារឆ្លងកាត់

### ១_ សេចក្តីផ្តើម

អេស្កាប់ ផ្តល់ការគាំទ្រដល់សហគមន៍នៅតំបន់ជនបទ ដែលសិស្សពុំអាចមានលទ្ធភាពចូលរៀនបាន ដោយសាងសង់បន្ទប់រៀនដែលមានលក្ខណៈបណ្តោះអាសន្ន ដែលធ្វើអំពីសម្ភារដែលមាននៅនឹងមូលដ្ឋាន (ជាពិសេសធ្វើអំពីស្លឹក និងឬស្សី)។ នេះក៏ជាអន្តរាគមន៍មួយដែលមាននៅក្នុងបញ្ជីសកម្មភាពសាលាកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលជាដំណោះស្រាយបន្ទាន់ និងបណ្តោះអាសន្ន ទាក់ទងនឹងបញ្ហាកង្វះខាតសាលា/ថ្នាក់រៀន។ ការបង្កើតបន្ទប់រៀនមួយដែលមានលក្ខណៈបណ្តោះអាសន្នបែបនេះ ជាទូទៅតែងតែត្រូវបានផ្តល់គ្រូសហគមន៍ភ្ជាប់ជាមួយ ដើម្បីធ្វើឱ្យសេវាអប់រំនៅទីនោះ អាចដំណើរការបានក្នុងរយៈពេលបន្ទាន់ និងភ្លាមៗ។ យុទ្ធវិធីនេះ មានការងាយស្រួលនិងប្រសើរច្រើន ដោយពុំមានភាពទទើសទទែងដែលត្រូវឆ្លងកាត់យូរ ដែលតែងតែជួបប្រទះក្នុងគម្រោងសាងសង់សាលារៀននានា ដូចជាតម្រូវការក្នុងការធ្វើការវាយតម្លៃលើផលប៉ះពាល់ផ្នែកបរិដ្ឋាន ការសុំចុះបញ្ជីឈ្មោះជាមួយរដ្ឋាភិបាល និងដំណើរការសាងសង់ជាក់ស្តែងជាដើម ដោយមិនរាប់បញ្ចូលទាំងតម្រូវការពេលវេលាគ្គលិក ដូចមានចែងក្នុងរចនាសម្ព័ន្ធរដ្ឋនោះផងទេ។ ផ្សារភ្ជាប់ជាមួយនឹងការផ្តល់គ្រូសហគមន៍ និងសកម្មភាពលើកកំពស់ការចូលរួម របស់សហគមន៍ អេស្កាប់យល់ថា ការផ្តល់អាគារឆ្លងកាត់អាចឈោងដល់កុមារក្នុងចំនួនដ៏ច្រើន ក្នុងរយៈពេលដ៏ខ្លី។ ដូច្នេះការសាងសង់អាគារឆ្លងកាត់មានតួនាទីដ៏សំខាន់ ក្នុងការពង្រីកសេវាអប់រំ ឱ្យឈានដល់តំបន់ដាច់ស្រយាល។

### ២_ គោលបំណង

- បង្កើនការចូលរៀនសម្រាប់កុមារដែលរស់នៅតំបនដាច់ស្រយាល
- ចាត់ការយ៉ាងរហ័សក្នុងដមណើរការពង្រីកសេវាអប់រំ នៅតំបន់ដាច់ស្រយាល

### ៣_ ក្រុមគោលដៅ

ជាទូទៅ ការផ្តល់អាការឆ្លងកាត់គឺផ្តោតទៅលើកុមារតូចៗ ដែលមិនដែលបានចូលរៀន។ ពោលគឺកុមារដែលមិនទាន់ធំល្មម ក្នុងការដើរតាមផ្លូវនិងកាត់ព្រៃទៅសាលារៀន ហើយដែលធ្វើឱ្យពួកគេបាត់បង់ឱកាសក្នុងការចូលរៀន។ អាគារឆ្លងកាត់បង្កលក្ខណៈសម្រាប់សិស្សថ្នាក់ទី១ ទី២ និងទី៣ ព្រោះថាពួកគេទាំងនេះ ភាគច្រើនពុំមានឬអស់ឱកាសក្នុងការបន្តការសិក្សាទៅមុខទៀត។ លទ្ធភាពរបស់ អាគារឆ្លងកាត់ក៏អាចបំរើកុមារក្រៅពីថ្នាក់ទី១ ដូចជាកុមារថ្នាក់ទី២ ឬទី៣ជាដើម តាមបែបការបង្រៀនថ្នាក់គួប។

## ៤. អ្នកសម្របសម្រួល

ជាគោលការណ៍ ការសាងសង់អាគារឆ្លងកាត់ គួរតែត្រូវបានដឹកនាំដោយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ឬសហគមន៍មូលដ្ឋាន។ មេឃុំ ឬប្រធានភូមិ គួរសហការជាមួយសាលារៀនដែលជិតជាងគេ ឬកម្រងសាលា ដើម្បីទទួលថវិកាចំនួន៥០០ ដុល្លារ សម្រាប់ទិញសម្ភារសាងសង់អាគារឆ្លងកាត់។ សហគមន៍គួររួមចំណែកជួយជាកម្លាំងពលកម្ម ក្នុងការសាងសង់នេះ។ គណៈកម្មាការកម្រងសាលារៀនគួរសម្របសម្រួលក្នុងការបែងចែកគ្រូសហគមន៍ ដើម្បីឱ្យគាត់បង្រៀននៅទីនោះ។

## ៥. ព័ត៌មានក្នុងការអនុវត្ត

- នៅពេលធ្វើផែនការប្រចាំឆ្នាំនៅដើមឆ្នាំសិក្សា សាលារៀនត្រូវកំណត់តំបន់ ឬទីតាំងដែលកុមារភាគច្រើនមិនបានចូលរៀន។
- ក្រោយពីការកំណត់ទីតាំងដែលត្រូវការអាគារឆ្លងកាត់រួចហើយ ត្រូវគិតពីការលំអិតថវិកា ដោយផ្អែកទៅតាមរូបមន្តទូទៅក្នុងចំនួន៥០០ ដុល្លារ (មួយបន្ទប់)។
- បន្ទាប់ពីបើកអំណោយពីការិយាល័យកណ្តាល គណៈកម្មការកម្រងត្រូវផ្តល់អំណោយ៥០០ ដុល្លារនេះជាបន្ទាន់ទៅគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ឬសហគមមាតាបិតាសិស្ស។
- គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ឬសហគមមាតាបិតាសិស្សត្រូវទទួលខុសត្រូវ ក្នុងការចលនាសហគមន៍ ដើម្បីរួមចំណែកក្នុងការសាងសង់អាគារឆ្លងកាត់។ ពួកគាត់ត្រូវផ្សព្វផ្សាយនៅក្នុងភូមិផងដែរ ថាសាលារៀននឹងមានសេវាអប់រំនៅដើមឆ្នាំសិក្សា ឬនៅពេលខែឌលអាគារត្រូវបានសង់រួច។
- គណៈកម្មការកម្រងត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ /គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ក្នុងការបែងចែកគ្រូសហគមន៍ទៅតាមអាគារឆ្លងកាត់នីមួយៗ។